# ចំការក្រូចពោធិ៍សាត់នៅភ្នំក្រវាញ

## ចុះស្វែងយល់ចំការ លោក ខន ពន្លក

ថ្ងៃទី១៥មេសា២០១៩

ដោយ ត៉ន ប៊ុន ស៊ុយ

១. <u>ទីតាំង</u>៖ ភូមិវាលវង់ ឃុំរកាឌ ស្រុកក្រវាញ នៅចម្ងាយប្រហែល 40Km ពីក្រុងពោធិ៍សាត់ និង1.5Km ខាងក្រោមទំនប់ទី៥

Co-ordinates: 12degrees16’07.6” **N** x 103degrees42’44.4”**E**




ស្ថានភាពដីចំការនៅជើងភ្នំ

២.<u>ដាំ</u> ពីខែកញ្ញា ២០១៤ មកដល់ពេលនេះបាន 5ha (2000ដើម) គម្លាត 5m x 5m

កូនបំបៅ ជើងទំរ (rootstock)៖ក្រូចឆ្មារជប៉ុន

៣.<u>ជី</u>15 x 15 x 15     100g ក្នុង ១ដើម

៤.<u>ថ្នាំការពារសត្វល្អិត</u>៖ ViCiDi វីស៊ីឌី (**រូបថតទី៦**)

ប្រើ ២គម្រប ក្នុងទឹក ២០លីត្រ

បាញ់ ៣ដង ចាប់ពីក្រូចក្តិបដល់ផ្លែចាស់

៥.ស្រោចស្រព ពេលរាំងស្ងួត បូមទឹកពីអូរកាឌ

ធម្មតា ភ្លៀងធ្លាក់រាល់ខែ

ខែប្រាំង យ៉ាងតិចភ្លៀងធ្លាក់ ១ដង

៦.ដីព្រៃ ឆ្ការមុនដាំ (ស្ថានភាពដីចំការនៅជើងភ្នំ)

វាយនភាព (texture)៖ ខ្សាច់ល្បាយ ខ្សាច់ម៉ដ្ឋ

ពណ៌ ប្រផេះស្រាល

ដីជ្រៅ យ៉ាងតិច 1m

ទំរង់ (structure)គ្រាប់ដាច់ពីគ្នា

៧.ស្ថានភាពដំណាំ

បើប្រៀបធៀបទៅនឹងចំការរូង(បាត់ដំបង)ដុះយឺតបន្តិច។ស្លឹកពណ៌ខៀវចាស់មិនខុសពីក្រូចនៅចំការរូង ទេតែស្លឹកតូចជាង។**(រូបថតទី១, ទី២ និងទី៣)**

ក្រូច២ដើមក្នុងចំណោមក្រូច៥០ដើមដែលយើងបានឃើញចេញស្លឹកប្រាក់គ្រប់មែកលូតលាស់យឺតដើមតូចជាងដើមឯទៀត។**(រូបថតទី៤)**

មែកនៅកណ្តាលថ្ងៃផ្លែចេញពណ៌លឿងក្រហម**(រូបថតទី៥)**

៨.ការសន្និដ្ឋាន

-កត្តាអំណោយផល៖ បរិយាកាសព្រៃភ្នំ ភ្លៀងច្រើនជាងនៅបាត់ដំបង

-នៅជើងភ្នំ ទទួលជីជាតិ និងទឹក ហូរច្រោះតាមជម្រាលភ្នំ

-កត្តាអវិជ្ជមាន

ដីខ្សាច់ ឆាប់អស់ជីជាតិដែលព្រៃមានបន្សល់ទុក។

ផ្លូវមួយកំណាត់ជាផ្លូវលំ ពិបាកធ្វើដំណើរ។

-ជាសរុបក្នុងឆ្នាំដំបូង ជម្ងឺមិនទាន់រាលដាលនៅឡើយទេ តែបានចាប់ផ្តើមហើយដូច្នេះ គួរចាត់ វិធានការម៉ឹងម៉ាត់ ដកដើម និងកាត់មែកឈឺយកទៅដុតចោល និងបាញ់ថ្នាំសម្លាប់សត្វល្អិតឲ្យបានច្រើនដងជាងសព្វថ្ងៃ។



រូបថតទី១៖ ចំការវាលវង់ ភ្នំក្រវ៉ាញ ក្រូចអាយុ ៥ឆ្នាំ ឥតមានជម្ងឺ



រូបថតទី២៖ ចំការវាលវង់ ភ្នំក្រវ៉ាញ ក្រូចអាយុ ៥ឆ្នាំ ស្លឹកខៀវក្រម៉ៅ ឥតមានជម្ងឺ



រូបថតទី៣៖ ចំការវលវង់ ភ្នំក្រវ៉ាញ ស្លឹកលូតលាស់ល្អ ផ្លែសឹងបាក់មែក



រូបថតទី៤៖ ចំការវាលវង់ ភ្នំក្រវ៉ាញ ក្រូចឈើ ស្លឹកលឿងគ្រប់មែក



រូបថតទី៥៖ ចំការវាលវង់ ភ្នំក្រវ៉ាញ មែកក្រោមកម្តៅថ្ងៃខ្លាំង ផ្លែចេញពណ៌លឿង ក្រហម




រូបថតទី៦៖ ចំការវាលវង់ ក្រវ៉ាញ ថ្នាំកំចាត់សត្វល្អិត ViCIDI វីស៊ីឌី ២គម្រប ទឹក២០លីត្រ